**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ០៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតនាយកដ្ឋានស្រាវជ្រាវឧបករណ៍សម្ភារៈបច្ចេកទេសនគរបាល នៃក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត ០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អ.ន.ក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៤៦ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការបង្កើតអគ្គនាយកដ្ឋានកស្តុភារនិងហិរញ្ញវត្ថុ នៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ ៖** ត្រូវបានបង្កើត នាយកដ្ឋានស្រាវជ្រាវឧបករណ៍សម្ភារៈបច្ចេកទេសនគរបាល ចំណុះផ្ទាល់អគ្គនាយកដ្ឋានកស្តុភារនិងហិរញ្ញវត្ថុ នៃក្រសួងមហាផ្ទៃ ។

ការបង្កើត នាយកដ្ឋានស្រាវជ្រាវឧបករណ៍សម្ភារៈបច្ចេកទេសនគរបាល នេះក្នុងទិសដៅដើម្បីស្រាវជ្រាវផ្តល់គំនិតក្នុងការផ្គត់ផ្គង់បំពាក់នូវឧបករណ៍សម្ភារៈបច្ចេកទេសទំនើបៗ ឆ្លើយតបទៅនឹងសភាពការណ៍ចំពោះមុខ និងយូរអង្វែងដល់កងកំលាំងនគរបាលជាតិ ពិសេសបង្កើនសមត្ថភាពនិងប្រសិទ្ធិភាពនៃកិច្ចប្រតិបត្តិការ បង្ការ បង្ក្រាបបទល្មើសគ្រប់ប្រភេទក្នុងភារកិច្ច ការពារសន្តិសុខ រក្សាសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈសង្គម ។

**មាត្រា២ ៖** នាយកដ្ឋានស្រាវជ្រាវឧបករណ៍សម្ភារៈបច្ចេកទេសនគរបាល មានសមត្ថកិច្ច និងភារកិច្ចដូចតទៅ ៖

- ធ្វើជាសេនាធិការជូនអគ្គនាយកដ្ឋានកស្តុភារនិងហិរញ្ញវត្ថុ ក្នុងការស្រាវជ្រាវស្វែងរកឧបករណ៍សម្ភារៈបច្ចេកទេសទំនើបៗ ដើម្បីបំពើឲ្យសំណូមពរនៃកិច្ចការចំពោះមុខ និងយូរអង្វែងដល់កងកំលាំងនគរបាលជាតិសំរាប់កិច្ចប្រតិបត្តិការបង្ការ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ ។

- វាយតំលៃអំពីការលំបាក ភាពចាំបាច់ និងតម្រូវការនូវឧបករណ៍ សម្ភារៈ បច្ចេកទេស និងសំណូមពរតាមបណ្តាអង្គភាពជំនាញនីមួយៗក្នុងកងកំលាំងនគរបាលជាតិ តាមកាលៈទេសៈជាក់ស្តែង ។
- ស្រាវជ្រាវពីភាពរីកចំរើននៃការបំពាក់ និងប្រើប្រាស់ឧបករណ៍ សម្ភារៈ តាមបច្ចេកវិទ្យាទំនើបៗរបស់បណ្តាកងកំលាំងនគរបាលនៅតាមប្រទេសនានាលើសកលលោក ។
- សិក្សាអំពីសំណូមពរស្នើសុំការបំពាក់ឧបករណ៍សម្ភារៈបច្ចេកទេសទំនើបៗដល់កងកំលាំងនគរបាលជាតិ តាមអង្គភាពជំនាញនីមួយៗ ។
- ប្រតិបត្តិតាមការប្រគល់ភារកិច្ចពីថ្នាក់ដឹកនាំអគ្គនាយកកស្តុភារនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ក្នុងការទំនាក់ទំនងជាមួយអង្គការជាតិ-អន្តរជាតិ និងក្រុមហ៊ុនឯកជន ដើម្បីស្វែងរកការផ្តល់បទពិសោធន៍ ពត៌មានអំពីបច្ចេកវិទ្យានានា និងដើម្បីផ្គត់ផ្គង់នូវឧបករណ៍ សម្ភារៈ បច្ចេកទេសទំនើបប្រើប្រាស់ក្នុងមុខជំនាញនគរបាល ។
- សហការវាយតំលៃពីកំរិតសមត្ថភាពជំនាញរបស់កងកំលាំងនគរបាលជាតិយើង ក្នុងការប្រើប្រាស់នូវឧបករណ៍ សម្ភារៈ បច្ចេកទេសនានា ។
- សហការវាយតំលៃបូកសរុបអំពីកំរិតគុណភាព បរិមាណនិងកំរិតបទដ្ឋានបច្ចេកទេស នូវរាល់ឧបករណ៍សម្ភារៈបច្ចេកទេសដែលមន្ត្រីនគរបាលតាមបណ្តាអង្គភាពជំនាញនានាបាននឹងកំពុងប្រើប្រាស់ ។
- លើកគំពោងបើកវគ្គបណ្តុះបណ្តាល ហ្វឹកហ្វឺន និងបំប៉នដល់មន្ត្រីនគរបាលជំនាញនីមួយៗ ដើម្បីបង្កើនកំរិតយល់ដឹងក្នុងការប្រើប្រាស់ និងការថែទាំឧបករណ៍ សម្ភារៈ បច្ចេកទេសដែលបានបំពាក់ឲ្យ ។
- តាមដានការប្រើប្រាស់រាល់ឧបករណ៍សម្ភារៈច្ចេកទេស ដែលបានផ្គត់ផ្គង់ទៅតាមបណ្តាអង្គភាព ដើម្បីធានាបានតាមបទដ្ឋានបច្ចេកទេសជំនាញ និងប្រសិទ្ធិភាពការងារ ។
- ផ្តើមយោបល់ជូនថ្នាក់ដឹកនាំអំពីការផ្គត់ផ្គង់បំពាក់ឧបករណ៍ សម្ភារៈ បច្ចេកទេស ផ្តល់ដល់អង្គភាពជំនាញស្របតាមកាលៈទេសៈរយៈពេលខ្លី-វែង ចំពោះមុខ និងយូរអង្វែង សមស្របតាមសភាពការណ៍វិវត្តន៍ក្នុងប្រទេស និងសកលលោក ។
- គ្រប់គ្រងថែរក្សានិងជួសជុលឧបករណ៍សម្ភារៈបច្ចេកទេសទៅតាមបទដ្ឋានបច្ចេកទេសជំនាញ ។
- បំពេញការងារបុគ្គលិក ការងាររដ្ឋបាល និងការងារកេស្តុភារ-គណនេយ្យរបស់នាយកដ្ឋានស្រាវជ្រាវឧបករណ៍សម្ភារៈបច្ចេកទេសនគរបាលតាមការកំណត់របស់ក្រសួងមហាផ្ទៃ ។
- អនុវត្តភារកិច្ចផ្សេងៗដែលអគ្គនាយកកស្តុភារនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃប្រគល់ឲ្យ ។

**មាត្រា ៣ ៖** នាយកដ្ឋានស្រាវជ្រាវឧបករណ៍សម្ភារៈបច្ចេកទេសនគរបាល ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយតាមការចាំបាច់ក្នុងការងារដឹកនាំនាយកដ្ឋាន ។

**មាត្រា ៤ ៖** នាយកដ្ឋានស្រាវជ្រាវឧបករណ៍សម្ភារៈបច្ចេកទេសនគរបាល មានការិយាល័យជំនាញមួយចំនួនចំណុះ ។ ការរៀបចំរចនាសម្ព័ន្ធ តួនាទី ភារកិច្ច ការរៀបចំក្របខណ្ឌមន្ត្រីរបស់ការិយាល័យជំនាញចំណុះនាយកដ្ឋានស្រាវជ្រាវឧបករណ៍សម្ភារៈបច្ចេកទេសនគរបាល ត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៥ ៖** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែមករា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>**កន្លែងទទួល**</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- ឯកសារ-កាលប្បវត្តិ ✓